**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ១០១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការទទួលស្គាល់គណៈកម្មាធិការកណ្តាល អាណត្តិទី ៣ សមាជិកបំរុង, ឥស្សរជន និង អគ្គលេខាធិការដ្ឋាន កាកបាទក្រហមកម្ពុជា

&&&&&

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ រកត /១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ៣៧៨ / នស ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ១៩៩៨ ស្តីពីការទទួលស្គាល់សមាគមជាតិកាកបាទក្រហមកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៥០២/១១២ ចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការប្រើប្រាស់ និងការការពាររូបសញ្ញាកាកបាទក្រហម និងអឌ្ឍចន្ទក្រហម
- បានឃើញព្រះរាជក្រឹត្យ លេខ នស /រកត / ០៥០២/១១៣ ចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការទទួលស្គាល់កាកបាទក្រហមកម្ពុជា
- បានឃើញកំណត់ហេតុ ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០២ របស់អង្គមហាសន្និបាតកាកបាទក្រហមកម្ពុជាលើកទី ៣ នាថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការជ្រើសតាំងសមាសភាពគណៈកម្មាធិការកណ្តាល ថ្មី អាណត្តិទី ៣
- យោងលិខិតលេខ ៥៣២-កក្រក.រ ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០០២ ស្តីពីការទទួលស្គាល់សមាជិក បំរុងនៃគណៈកម្មាធិការកណ្តាល និងឥស្សរជន របស់កាកបាទក្រហមកម្ពុជា
- យោងតាមសំណើរបស់ប្រធានគណៈកម្មាធិការកណ្តាលកាកបាទក្រហមកម្ពុជា លេខ ៤៦៧-កក្រក.រ ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០២

# សំរេច

**មាត្រា ១** : ទទួលស្គាល់គណៈកម្មាធិការកណ្តាល អាណត្តិទី ៣, សមាជិកបំរុង, ឥស្សរជន និង អគ្គលេខាធិការដ្ឋាន កាកបាទក្រហមកម្ពុជា ដូចមានសមាសភាពខាងក្រោម :

១-១ :. **គណៈកម្មាធិការកណ្តាល** :

| | | |
|---|---|---|
| ១- លោកជំទាវ | **ប៊ុន រ៉ានី ហ៊ុន សែន** | ប្រធាន |
| ២- ឯកឧត្តម | អ៊ុក ដាមរី | អនុប្រធានទី ១ |
| ៣- លោកជំទាវ | អាន្នី សុខ អាន | អនុប្រធានទី ២ |
| ៤- លោកជំទាវ | អ៊ុក ម៉ាលី | អគ្គហេរញ្ញិក |
| ៥- ឯកឧត្តម | គង់ សំអុល | សមាជិក |
| ៦- ឯកឧត្តម | ញ៉ឹម វណ្ណដា | សមាជិក |
| ៧- ឯកឧត្តម | ឈុន ស៊ីរុន | សមាជិក |
| ៨- លោកជំទាវ | ឃួន សុដារី | សមាជិកា |
| ៩- លោកជំទាវ | អ៊ុន សុគន្ធា | សមាជិកា |
| ១០- លោកជំទាវ | ពៅ៉ម សុផានី ងួន ញ៉ិល | សមាជិកា |
| ១១- ឯកឧត្តម | ហោ កាន់ | សមាជិក |
| ១២- ឯកឧត្តម | ហេង តៃគ្រី | សមាជិក |
| ១៣- ឯកឧត្តម | អ៊ីវ ចុង | សមាជិក |
| ១៤- ឯកឧត្តម | ងី ច័ន្ទ្រផល | សមាជិក |
| ១៥- ឯកឧត្តម | ម៉ៅ អាយុទ្ធ | សមាជិក |

១-២ : **សមាជិកបំរុង** :

| | |
|---|---|
| ១- លោកជំទាវ | ហូ ណួន |
| ២- លោកជំទាវ | ជឹង សុភាព |
| ៣- លោកជំទាវ | អៀង សេដ្ឋ មូលី |

១-៣ : **ឥស្សរជន** :

| | |
|---|---|
| ១- លោកជំទាវ | ទៀ បាញ់ |
| ២- លោកជំទាវ | ច័ន្ទ សារុន |
| ៣- លោកឧកញ៉ា | ម៉ក់ គីមហុង |

១-៤ : **អគ្គលេខាធិការដ្ឋាន :**

| | | |
|---|---|---|
| ១- ឯកឧត្តម | មី សាមិឌី | អគ្គលេខាធិការ |
| ២- លោកជំទាវ | ពុំ ចន្នីធី | អគ្គលេខាធិការរងទី ១ |
| ៣- លោកវេជ្ជបណ្ឌិត | ង៉ូង សាខុន | អគ្គលេខាធិការរងទី ២ |

**មាត្រា ២ :** គណៈកម្មាធិការកណ្តាលកាកបាទក្រហមកម្ពុជា ដែលបានជ្រើសរើសតាមការបោះឆ្នោត របស់មហាសន្និបាតទូទាំងប្រទេស នៅថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០២ ត្រូវបំពេញភារកិច្ចទៅតាមអំណាចដែលមានចែងនៅក្នុងមាត្រា ១៥ នៃលក្ខន្តិកៈ របស់កាកបាទក្រហមកម្ពុជា ។

**មាត្រា ៣ :** អគ្គលេខាធិការ ដែលជ្រើសតាំងដោយគណៈកម្មាធិការកណ្តាល ត្រូវបំពេញភារកិច្ចទៅតាម មុខនាទីដែលមានចែងនៅក្នុងមាត្រាទី ២១ នៃលក្ខន្តិកៈ របស់កាកបាទក្រហមកម្ពុជា ។

**មាត្រា ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានកាកបាទក្រហមកម្ពុជា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ អភិបាលខេត្ត-ក្រុង ដែលពាក់ព័ន្ធ និងដូចមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

__កន្លែងទទួល :__

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាននៃព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាននៃរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- ឯកសារ - កាលប្បវត្តិ